**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ៣៨៦ ពាណ.ណ.ជសព

ថ្ងៃអង្គារ ៩ កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០២៣

# សេចក្តីជូនដំណឹង
## ស្តីពី
## យន្តការលើកទឹកចិត្តនានា សម្រាប់ការចុះបញ្ជីពាណិជ្ជកម្មដោយស្ម័គ្រចិត្ត របស់វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូន លោក-លោកស្រី ដែលកំពុងប្រកបអាជីវកម្មក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ មេត្តាជ្រាបថា បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដាក់ឱ្យអនុវត្តនូវ «យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨» និងយោងតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាកម្មវិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនៃយុទ្ធសាស្ត្រជាតិនេះ ក្រសួងពាណិជ្ជកម្ម បានសម្រេចផ្តល់ការលើកទឹកចិត្តទៅដល់លោក-លោកស្រី ដែលមានបំណងចុះបញ្ជីប្រកបអាជីវកម្មជាសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដើម្បីអាចទទួលបានការគាំទ្រនានាពីរាជរដ្ឋាភិបាលដូចជា៖

- ១. ការលើកលែងកាតព្វកិច្ចអនុលោមភាព និង
- ២. ការលើកលែងការផាកពិន័យនានា សម្រាប់អាជីវកម្មដែលបានដំណើរការ និងមិនបានចុះបញ្ជីត្រឹមត្រូវ

សេចក្តីដូចបានជម្រាបជូនខាងលើ ក្រសួងពាណិជ្ជកម្ម មានជំនឿយ៉ាងមុតមាំថា លោក-លោកស្រី ជាអាជីវករទាំងអស់ដែលប្រកបអាជីវកម្មក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ នឹងចូលរួមដោយស្ម័គ្រចិត្តក្នុងការចុះបញ្ជី ដើម្បីចូលក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធយ៉ាងផុសផុលជាមិនខាន។

សម្រាប់ព័ត៌មានលម្អិតសម្រាប់ការដាក់ពាក្យស្នើសុំតាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្មនេះ លោក-លោកស្រី អាចចូលទៅកាន់គេហទំព័រ www.registrationservices.gov.kh (ដូចមានជូនភ្ជាប់ QR កូដខាងក្រោម) ឬអាចធ្វើការទំនាក់ទំនងផ្ទាល់ទៅកាន់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម តាមរយៈលេខទូរស័ព្ទ ០៩៦ ៩៦៣ ២៣៦៣ ឬ ០៨៨ ៦០៨៣ ០៨២។

| | |
|---|---|
| លេខទូរស័ព្ទ | (+៨៥៥) ៩៦ ៩៦៣ ២៣៦៣ |
| | (+៨៥៥) ៨៨ ៦០៨៣ ០៨២ |
| គេហទំព័រ | www.registrationservices.gov.kh |

សូមអរគុណ!